# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សាលក្រមព្រហ្មទណ្ឌ
លេខ ១៣ "ច១" ក្រ១០
ចុះថ្ងៃទី ១១.០១.២០២៣
-សំណុំរឿងព្រហ្មទណ្ឌ
លេខ ៨១១
ចុះថ្ងៃទី ១៦.០២.២០២២
-សំណុំរឿងស៊ើបសួរ
លេខ ៥៧២
ចុះថ្ងៃទី ១៧.០២.២០២២
-សំណុំរឿងជំនុំជម្រះ
លេខ ២៦៤៨
ចុះថ្ងៃទី ១៤.០៧.២០២២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង០២ និង ៣០នាទីរសៀល សាលសវនាការទី៩ ដោយមានសមាសភាព៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោក [redacted] ប្រធានក្រុមប្រឹក្សា

-លោក [redacted] ចៅក្រមប្រឹក្សា

-លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**ដើម្បីជំនុំជម្រះ**

សំណុំរឿងព្រហ្មទណ្ឌលេខ ៨១១ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២ ដែលមាន៖

ជនជាប់ចោទឈ្មោះ [redacted] **ចាន់ណារី** ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ មុខរបរនៅផ្ទះ ទីកន្លែងកំណើត ភូមិក្រាំ[redacted] ខេត្តកណ្តាល ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅ ភូមិក្រាំង[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] **សារឿន** "រ" ម្តាយឈ្មោះ [redacted] **រចនា** "រ" ជានីតិជន ទោសពីមុនគ្មាន **(គេចខ្លួន)** ។

-ដីកាបង្គាប់ឱ្យឃុំលេខ ១៣៦១ "ជ១" ដ.ឃ.ដ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ **(ឃុំខ្លួននៅពន្ធនាគារ រាជធានីភ្នំពេញ PJ)** ។

ជាប់ចោទពីបទ **លួចមានស្ថានទម្ងន់ទោស (ប្រើកាំបិត ច្រវ៉ាក់ ដាច់កៃច្នៃ វាយយកម៉ូតូ)** ប្រព្រឹត្តនៅចំណុច ខាងត្បូងស្តុបទួលពង្រ ស្ថិតនៅភូមិ២៤ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា **៣៥៣** និង មាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ ។

លោកមេធាវី [redacted]ការិយាល័យមេធាវី [redacted] មានអាសយដ្ឋាន ផ្ទះលេខ១១០សេដេ ផ្លូវលេខ៣៦០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ **ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ** ។



Scanned with CamScanner

លោកមេធាវី [redacted] ការិយាល័យមេធាវី [redacted] អាសយដ្ឋាន ផ្ទះលេខH៣៥ ផ្លូវH(វីវីរ៉ា) ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ **ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ** ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **វាសនា** ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅស្នាក់នៅ ភូមិ២៤ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] កុសល ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅស្នាក់នៅ ភូមិត្រពាំងចេក សង្កាត់ចោមចៅ២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

-បានឃើញដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ **៥៩៥ អ.យ.ឋ** ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ **២២៣៨ អ.យ.ឋ** ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៣០៨៦ "ជ១" ដ.ដ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## <u>អង្គហេតុនៃរឿងមានដូចតទៅ</u>

កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង៤ និង០០នាទី នៅចំណុចមុខ ខាងត្បូងវត្តទួលពង្រ ស្ថិតនៅភូមិ២៤ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ មានករណី **លួចមានស្ថានទម្ងន់ទោស (ប្រើកាំបិត ច្រវ៉ាក់ ដាវកែឆ្នៃ វាយយកម៉ូតូ)** បង្កឡើងដោយជនសង្ស័យមួយក្រុមមានឈ្មោះ [redacted] **ចាន់ណារី** ភេទប្រុស អាយុ ៣៧ឆ្នាំ ឈ្មោះ **ម៉ាប់** ភេទប្រុស និងបក្ខពួក ។ មុនពេលកើតហេតុ ក្រុមជនសង្ស័យបានជុំគ្នាផឹកស៊ីរហូតដល់ម៉ោងជិត៤ រួចនាំគ្នាជិះម៉ូតូចេញមកដល់ចំណុចកើតហេតុខាងលើ ក៏ធ្វើសកម្មភាពវាយជនរងគ្រោះឈ្មោះ [redacted] **វាសនា** និងឈ្មោះ [redacted] កុសល ដោយប្រើកំបិត ច្រវ៉ាក់ ដាវកែឆ្នៃវាយ ទើបជនរងគ្រោះផ្តួលម៉ូតូរត់គេចខ្លួន ហើយជនសង្ស័យឈ្មោះ [redacted] **ចាន់ណារី** ជិះម៉ូតូជាមួយឈ្មោះ **ម៉ាប់** បានចុះទៅលើកម៉ូតូរបស់ជនរងគ្រោះបម្រុងជិះគេចខ្លួន តែត្រូវជនរងគ្រោះស្រែកផ្អើលអោឡោឱ្យសមត្ថកិច្ចឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] **ចាន់ណារី** រីឯឈ្មោះ **ម៉ាប់** និងបក្ខពួក នាំគ្នាគេចខ្លួនបាត់ ។ សមត្ថកិច្ចឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] **ចាន់ណារី** និងកសាងសំណុំរឿងរួមទាំងវត្ថុតាងបញ្ជូនមកតុលាការ ។

## <u>នាពេលសវនាការ</u>

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] **ចាន់ណារី** បានឆ្លើយថា៖ កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង០៤ និង០០នាទី ឈ្មោះ **ម៉ាប់** ជិះម៉ូតូម៉ាកឌុបជ្រុង ពណ៌ទឹកប៊ិច មិនចាំផ្លាកលេខ មកឌុបខ្លួន និងបានមកផឹកស៊ីជុំគ្នា៧នាក់ ទើបឈ្មោះ **ម៉ាប់** ឌុបខ្លួនមកដល់ចំណុចខាងត្បូងស្តុបទួលពង្រ ស្ថិតនៅភូមិ២០ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ឃើញម៉ូតូចំនួន០២គ្រឿងដួលលើផ្លូវ ឈ្មោះ **ម៉ាប់** បើកម៉ូតូក្រឡឹងជុំវិញ ខ្លួនក៏ចុះពីលើម៉ូតូទៅលើកម៉ូតូម៉ាក HONDA ZOOMER X 110 ពណ៌ខៀវ ពាក់ផ្លាកលេខ ភ្នំពេញ 1FZ-2158 បម្រុងគេចខ្លួនស្រាប់តែម្ចាស់គេស្រែកថាចោរៗ ហើយសមត្ថកិច្ចចាប់ខ្លួនបានតែម្តង រីឯឈ្មោះ **ម៉ាប់** គេចខ្លួនបាត់ ។



Scanned with CamScanner

-អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] កុសល បានឆ្លើយថា៖ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង០៤ និង០០នាទី ខ្លួនបានជិះម៉ូតូម៉ាក ស៊ុយសេគីនិច ពណ៌ស ពាក់ផ្លាកលេខ 1DF-5486 ឌុបឈ្មោះ [redacted] **សំអឿង** និងមិត្តភក្តិឈ្មោះ [redacted] **វាសនា** ជិះម៉ូតូម៉ាក HONDA ZOOMER X 110 ពណ៌ខៀវ ពាក់ផ្លាកលេខ 1FZ-2158 បាននាំគ្នាមកដល់ចំណុចខាងត្បូងស្តុបទួលពង្រ ស្ថិតនៅភូមិ២០ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ស្រាប់តែក្រុមសង្ស័យប្រហែល១៥នាក់ ជិះម៉ូតូប្រហែល៧គ្រឿង មានប្រុស-ស្រី មានកាន់ដាវដំបង និងច្រវ៉ាក់ ដេញវាយពួកខ្លួន ពួកខ្លួនផ្តួលម៉ូតូគេចខ្លួន ហើយពួកវាក៏បានវាយ និងកាប់ពួកខ្លួន ។

-អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **វាសនា** បានឆ្លើយថា៖ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង០៤ និង០០នាទី ខ្លួនបានជិះម៉ូតូម៉ាក HONDA ZOOMERX110 ពណ៌ខៀវ ពាក់ផ្លាកលេខ 1FZ-2158 និងមិត្តភក្តិឈ្មោះ [redacted] កុសល ជិះម៉ូតូម៉ាក ស៊ុយស៊ូគីនិច ពណ៌ស ពាក់ផ្លាកលេខ 1DF-5486 ឌុបឈ្មោះ [redacted] **សំអឿន** បាននាំគ្នាមកដល់ចំណុចខាងត្បូងស្តុបទួលពង្រ ស្ថិតនៅភូមិ២០ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ស្រាប់តែក្រុមសង្ស័យប្រហែល១៥នាក់ ជិះម៉ូតូប្រហែល៧គ្រឿង មានប្រុស-ស្រី មានកាន់ដាវដំបង និងច្រវ៉ាក់ ដេញវាយពួកខ្លួន ពួកខ្លួនផ្តួលម៉ូតូគេចខ្លួន ហើយពួកវាក៏បានដេញវាយ និងកាប់ពួកខ្លួន ខ្លួនក៏ផ្តួលម៉ូតូរត់គេចពីពួកវា ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ឆ្លងតាមអង្គសវនាការ ចម្លើយរបស់ជនជាប់ចោទ អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងពិនិត្យសំណុំរឿងបញ្ជាក់ឱ្យឃើញថាមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **ចាន់ណារី** ភេទប្រុស អាយុ៣៧ឆ្នាំ ពីបទ៖ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុច ខាងត្បូងស្តុបទួលពង្រ ស្ថិតនៅភូមិ២៤ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ ។

-មេធាវី [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា៖ កូនក្តីរបស់ខ្លួនពុំមានវត្តមាននៅក្នុងអង្គសវនាការ ដោយពុំអាចឱ្យក្រុមប្រឹក្សាជំនុំជម្រះសួរដេញដោលអំពីអង្គហេតុពិតប្រាកដបានឡើយ ហេតុដូច្នេះពុំអាចចាត់ទុកថាកូនក្តីរបស់ខ្លួនមានពិរុទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តន្ទាទោសបានទេ ។ វិមតិសង្ស័យត្រូវបានផលប្រយោជន៍ដល់ជនជាប់ចោទ ហេតុច្នេះស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណា ឱ្យកូនក្តីរបស់ខ្លួនរួចផុតបទចោទ ។

-ក្រោយពីបានស្តាប់អំណានចម្លើយសារភាពរបស់ជនជាប់ចោទ ។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា ។

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## **សំអាងហេតុ**

-**តាមមាត្រា ៣៥៣** នៃក្រមព្រហ្មទណ្ឌចែងថា **អំពើលួច** គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។

-**តាមមាត្រា ៣៥៧** នៃក្រមព្រហ្មទណ្ឌ ចែងថា អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំទៅ១០ (ដប់) ឆ្នាំ ក្នុងករណីដូចតទៅ:

១-អំពើលួចនេះ ប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬក្រោយពេលប្រើហិង្សា ។

២-អំពើលួចនេះ ប្រព្រឹត្តដោយការកាប់គាស់ទម្លុះទម្លាយ ។

-យល់ឃើញពីហេតុការណ៍ប្រព្រឹត្តនៃបទល្មើស កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង០៤ និង០០នាទី នៅចំណុច ខាងត្បូងស្តុបទួលពង្រ ស្ថិតនៅភូមិ២៤ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ពិតជាមានករណី **លួចមានស្ថានទម្ងន់ទោស** ដែលបង្កឡើងដោយឈ្មោះ [redacted] **ចាន់ណារី** ភេទប្រុស អាយុ៣៧ឆ្នាំ និងឈ្មោះ **ម៉ាប់** បានធ្វើសកម្មភាព **វាយប្លន់បម្រុងយកម៉ូតូ** របស់ជនរងគ្រោះឈ្មោះ [redacted] **វាសនា** និងឈ្មោះ [redacted] **កុសល** ហើយក៏ត្រូវជនរងគ្រោះស្រែកឆោឡោផ្តើលដល់សមត្ថកិច្ច ឃាត់ខ្លួនបានឈ្មោះ [redacted] **ចាន់ណារី** ម្នាក់ និងកសាងសំណុំរឿងបញ្ជូនមកតុលាការចាត់ការតាមនីតិវិធី ។

-តាមរបាយការណ៍សំយោគលេខ **០១៤/២០២២** **រ.ប.ក** ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌដង្កោ បានសន្និដ្ឋានថាជនសង្ស័យឈ្មោះ [redacted] **ចាន់ណារី** ភេទប្រុស អាយុ៣៧ឆ្នាំ ពិតជាបានប្រព្រឹត្តបទល្មើស **លួចមានស្ថានទម្ងន់ទោសដោយប្រើការអំពើហិង្សា (ប្រើកាំបិត ច្រវ៉ាក់ ដាវកែច្នៃកាប់ និងវ៉ៃប្លន់យកម៉ូតូ)** របស់ជនរងគ្រោះឈ្មោះ[redacted]សនា ភេទប្រុស អាយុ៣០ឆ្នាំ និងឈ្មោះ [redacted] កុសល ភេទប្រុស អាយុ១៨ឆ្នាំ កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ នៅចំណុច ខាងត្បូងវត្តទួលពង្រ ស្ថិតនៅភូមិម្តៃប្អូន សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រាកដមែន ។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ចាន់ណារី** នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ បានឆ្លើយសារភាពថាខ្លួនពិតជាបានប្រព្រឹត្តអំពើ **លួចមានស្ថានទម្ងន់ទោស** នៅចំណុច ខាងត្បូងវត្តទួលពង្រ ស្ថិតនៅភូមិ២៤ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ ពិតប្រាកដមែន ។

-អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ចាន់ណារី** បានឆ្លើយថា កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ ជនសង្ស័យឈ្មោះ [redacted] **ចាន់ណារី** និងបក្ខពួក ពិតជាបាននាំគ្នាប្រព្រឹត្តអំពើ **លួចមានស្ថានទម្ងន់ទោសដោយប្រើការអំពើហិង្សា (ប្រើកាំបិត ច្រវ៉ាក់ ដាវកែច្នៃកាប់ និងវ៉ៃប្លន់យកម៉ូតូ)** កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ នៅចំណុច ខាងត្បូងវត្តទួលពង្រ ស្ថិតនៅភូមិម្តៃប្អូន សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រាកដមែន ។

-តាមចម្លើយសារភាពរបស់ជនជាប់ចោទ អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី របាយការណ៍របស់នគរបាលយុត្តិធម៌ និងព្រមទាំងភស្តុតាងផ្សេងៗទៀតមានភាពស៊ីសង្វាក់គ្នាអាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] **ចាន់ណារី** ភេទប្រុស អាយុ៣៧ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ **លួចមានស្ថានទម្ងន់ទោស (ប្រើកាំបិត ច្រវ៉ាក់ ដាវកែច្នៃ វាយយកម៉ូតូ)** នៅចំណុច ខាងត្បូងវត្តទួលពង្រ ស្ថិតនៅភូមិម្តៃប្អូន សង្កាត់ព្រៃស ខណ្ឌ

ដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ ។

-យល់ឃើញថាសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ បានធ្វើសេចក្តីសន្និដ្ឋានដោយរក្សាការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលើជនជាប់ចោទទុកជាបានការដដែល និងស្នើសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **ចាន់ណារី** ភេទប្រុស អាយុ៣៧ឆ្នាំ ពីបទ **លួចមានស្ថានទម្ងន់ទោស (ប្រើកាំបិត ច្រវ៉ាក់ ដាវកែច្នៃ វាយយកម៉ូតូ)** នៅចំណុច ខាងត្បូងវត្តទួលពង្រ ស្ថិតនៅភូមិម្កៅបួន សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌមានមូលហេតុត្រឹមត្រូវ តុលាការគប្បីពិចារណា និងសម្រេចតាមច្បាប់ ។

-យល់ឃើញថាសេចក្តីសន្និដ្ឋានរបស់លោកមេធាវី [redacted] ធ្វើសេចក្តីសន្និដ្ឋានការពារឱ្យជនជាប់ចោទខាងលើ ដែលសុំឱ្យតុលាការសម្រេចឱ្យរួចផុតបទចោទនោះ ពុំមានមូលហេតុសមរម្យ អាចឱ្យតុលាការលើកយកមកពិចារណា និងសម្រេចតាមបានឡើយ ។

-តាមការស្តាប់ចម្លើយរបស់ជនជាប់ចោទ អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងការពិនិត្យភស្តុតាងយល់ឃើញថា៖

ក/ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ចាន់ណារី** គឺជាបទល្មើស **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ដែលមានចែងក្នុងបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ ។

ខ/ សកម្មភាពដែលស្តែងឡើងរបស់ជនជាប់ចោទឈ្មោះ [redacted] **ចាន់ណារី** បានធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិអ្នកដទៃ និងសន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសង្គមប៉ះពាល់ដល់ស្មារតីរបស់ប្រជាពលរដ្ឋ និងប៉ះពាល់ដល់សុខុមាលភាពផ្ទាល់ខ្លួន ជាពិសេសច្បាប់បញ្ញត្តិអំពើនេះជាបទល្មើស ។

គ/ អំពើរបស់ឈ្មោះ [redacted] **ចាន់ណារី** មានចេតនាទុច្ចរិត ក្នុងការប្រព្រឹត្តបទល្មើស **លួចមានស្ថានទម្ងន់ទោស** ដែលមានបំណងយកទ្រព្យសម្បត្តិរបស់អ្នកដទៃ មកធ្វើជាប្រយោជន៍ផ្ទាល់ខ្លួន ។

-យល់ឃើញពីសមត្ថភាពនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ផ្អែកតាមកាលៈទេសៈនៃបទល្មើស បុគ្គលិកលក្ខណៈរបស់ជនជាប់ចោទរូបនេះ ជានីតិជនមានស្មារតីគ្រប់គ្រាន់ ដោយពុំមានសញ្ញាណណាមួយបញ្ជាក់ថាមានបញ្ហាវិបល្លាសស្មារតីនោះឡើយ ដូច្នេះជនជាប់ចោទរូបនេះត្រូវទទួលខុសត្រូវនូវអំពើដែលខ្លួនបានប្រព្រឹត្តចំពោះមុខច្បាប់ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **វាសនា** និងឈ្មោះ [redacted] កុសល ពុំបានចូលខ្លួនក្នុងសវនការ និងពុំបានទាមទារសំណងអ្វីពីជនជាប់ចោទឡើយ ដូច្នេះតុលាការពុំគប្បីលើកបញ្ហានេះមកពិចារណា និងសម្រេចឡើយ ។

-តាមលិខិតលេខ ០០១/២២ ស.ដ.ក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌដង្កោ ដែលជាលិខិតរាយការណ៍ពីអធិការដ្ឋាននគរបាលខណ្ឌដង្កោ មកចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ស្តីពីករណីជនជាប់ចោទឈ្មោះ [redacted] ចាន់ណារី ភេទប្រុស អាយុ៣៧ឆ្នាំ បានប្រព្រឹត្តអំពើ **លួចមានស្ថានទម្ងន់ទោស (ប្រើកាំបិត ច្រវ៉ាក់ ដាវកែច្នៃ វាយយកម៉ូតូ)** នៅចំណុច ខាងត្បូងវត្តទួលពង្រ ស្ថិតនៅភូមិម្កៅបួន សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ រួចចៅក្រមស៊ើបសួរនៃសាលា



Scanned with CamScanner

ដំបូងរាជធានីភ្នំពេញ ក៏សម្រេចចេញដីកាបង្គាប់ឱ្យឃុំខ្លួន ប៉ុន្តែដោយសារស្ថានភាពជនជាប់ចោទកំពុងតែកើតជម្ងឺឆ្លងរាតត្បាតកូវីដ-១៩ ទើបសមត្ថកិច្ចនគរបាលនាំខ្លួនមកព្យាបាលសម្រាកនៅតំបន់៥ នៃមណ្ឌលអូឡាំពិក ។ លុះដល់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ វេជ្ជបណ្ឌិតនៃមណ្ឌលអូឡាំពិក បានចេញលិខិតអនុញ្ញាតឱ្យជនជាប់ចោទរូបនេះចេញពីមណ្ឌល ដោយពុំបានជូនដំណឹងមកសមត្ថកិច្ចនគរបាលឡើយ ។ ជនជាប់ចោទរូបនេះក៏បានគេចខ្លួនបាត់ ហេតុដូច្នេះគប្បីតុលាការចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ចាន់ណារី ភេទប្រុស អាយុ៣៧ឆ្នាំ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តាមនីតិវិធីច្បាប់ ។

-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ចាន់ណារី ភេទប្រុស អាយុ៣៧ឆ្នាំ ពីបទ៖ លួចមានស្ថានទម្ងន់ទោស (ប្រើកាំបិត ច្រវ៉ាក់ ដាវកែច្នៃ វាយយកម៉ូតូ) ប្រព្រឹត្តនៅចំណុច ផ្លូវព្រះស៊ីសុវត្ថិ កែងផ្លូវលេខ១៥៤ ភូមិ៦ សង្កាត់ផ្សារកណ្ដាលទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

១/. ផ្ដន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **ចាន់ណារី** ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ៥ (ប្រាំ) ឆ្នាំ ពីបទ៖ **លួចមានស្ថានទម្ងន់ទោស** (**ប្រើកាំបិត ច្រវ៉ាក់ ដាវកែច្នៃ វាយយកម៉ូតូ**) ប្រព្រឹត្តនៅចំណុច ខាងត្បូងស្តុបទួលពង្រ ស្ថិតនៅភូមិ២៤ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

២/. ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] ចាន់ណារី ភេទប្រុស អាយុ៣៧ឆ្នាំ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ចាន់ណារី និងកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] វាសនា និងឈ្មោះ [redacted] កុសល ប្រកាសជាសាធារណៈនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ គូភាគីមានសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃពុធ ៤កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]